ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

## សូមគោរពជូន
## សម្តេចក្រឡាហោម ស ខេង
## អនុប្រធានគណបក្សប្រជាជនកម្ពុជា និងជាឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមប្រពៃថ្លៃថ្លា ដែលសម្តេចត្រូវបានអង្គសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៣៨ អាណត្តិទី៥ នៃគណបក្សប្រជាជនកម្ពុជា បោះឆ្នោតជ្រើសតាំងជា **អនុប្រធានគណបក្ស** ខ្ញុំបាទសូមសម្តែងនូវសេចក្តីសោមនស្សរីករាយឥតឧបមា និងអំណរសាទរយ៉ាងជ្រាលជ្រៅ ជូនចំពោះ**សម្តេចក្រឡាហោម ស ខេង** អនុប្រធានគណបក្សប្រជាជនកម្ពុជា និងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ការបោះឆ្នោតប្រគល់តួនាទីដឹកនាំដ៏សំខាន់ ជូន**សម្តេចក្រឡាហោម** នាពេលនោះ គឺជាសក្ខីភាពឆ្លុះបញ្ចាំងឲ្យឃើញនូវសមត្ថភាពការងារដ៏ឧត្តុងឧត្តម ការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តប្រាជ្ញាស្មារតីពុះពារជំនះរាល់ឧបសគ្គនានាដោយភាពអង់អាចក្លាហាន ក្នុងការរួមចំណែកជាមួយថ្នាក់ដឹកនាំកំពូលៗរបស់គណបក្សប្រជាជនកម្ពុជា ដើម្បីដឹកនាំ ស្តារ និងអភិវឌ្ឍប្រទេសជាតិ រហូតសម្រេចបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ ឯករាជ្យជាតិ បូរណភាពទឹកដី និងមានការរីកចម្រើនលើគ្រប់វិស័យ។

ក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមគោរពជូនពរបវរមហាប្រសើរថ្លៃថ្លាបំផុតជូន **សម្តេចក្រឡាហោម និងលោកជំទាវ** ព្រមទាំងក្រុមគ្រួសារ សូមមានសុខភាពល្អបរិបូណ៌ ពលានុភាពខ្លាំងក្លា ប្រាជ្ញាវាងវៃ ព្រមទាំងទទួលបានជោគជ័យ និងសមិទ្ធផលជាប្រវត្តិសាស្ត្រកាន់តែត្រចះ ត្រចង់ ធំធេងថែមទៀត ក្នុងការបន្តដឹកនាំគណបក្សប្រជាជនកម្ពុជា និងនាវាកម្ពុជាក៏ដូចជាប្រជាជាតិកម្ពុជាទាំងមូល ឆ្ពោះទៅកាន់ត្រើយសុភមង្គល និងការអភិវឌ្ឍលើគ្រប់វិស័យ។

សូម **សម្តេចក្រឡាហោម ស ខេង** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ និងស្មោះស្ម័គ្របំផុត ពីខ្ញុំបាទ

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១៥

**សមាជិកគណៈកម្មាធិការកណ្តាល**

គង់ វិបុល